# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ រាជរដ្ឋាភិបាលខ្មែរប្រកាសថា ដីសូម្បី១មិល្លីម៉ែត្រក៏មិនឲ្យបាត់ទៅប្រទេសថៃឡើយ ។ ពាក្យនេះត្រូវអនុវត្តទៅប្រទេសវៀតណាមផង ។

www.hoksavann.org

ថ្ងៃទី១០ មីនា ២០១១



ពេលមានបញ្ហាជាមួយថៃអំពីបញ្ហាប្រាសាទព្រះវិហារនិងដីនៅជុំវិញព្រះវិហារ គ្រប់ស្ថាប័នខ្មែរ មានរាជរដ្ឋាភិបាលខ្មែរជាដើម មានគំនិតជាតិនិយមស្របគ្នាជាមួយប្រជាពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងគណបក្សក្រៅរដ្ឋាភិបាល ប្រឆាំងការឈ្លានពានរបស់ថៃ ការពារប្រាសាទព្រះវិហារនិងដីនៅជុំវិញប្រាសាទព្រះវិហារ ដោយស្របច្បាប់តាមតុលាការក្រុងឡាអេប្រទេសហូឡង់ ដែលកាត់ឲ្យខ្មែរឈ្នះក្តីកាលពីថ្ងៃទី១៥ មិថុនា ១៩៦២ ។ ក្នុងន័យនេះ ខ្មែរមានអំណាចស្របច្បាប់នៅក្នុងដៃ គឺទីមួយ ខ្មែរមានឯកភាពជាតិ និងទីពីរ ខ្មែរប្រឆាំងការការឈ្លានពានរបស់ថៃដោយស្របច្បាប់ ។

ការលើកយកបញ្ហាទឹកដីជាមួយវៀតណាមមកធ្វើការវិភាគក្នុងពេលនេះ ពុំមែនបានន័យថា បង្កើតសមរភូមិថ្មីមួយទៀតឡើយ តែសមរភូមិនេះកើតមានរួចមកហើយ គឺការវាស់បង្គោលព្រំដែនដូចគ្នារវាងខ្មែរនិងប្រទេសទាំងបី គឺវៀតណាម ថៃ និងលាវ ។ បើវាស់ឲ្យត្រឹមត្រូវមានយុត្តិធម៌ ឈ្មោះថាឈ្នះទាំងអស់គ្នា គឺឈ្នះទាំងខ្មែរ ទាំងប្រទេសទាំងបីនៅជុំវិញខ្មែរ ។ បើខ្មែរអ្នកទទួលខុសត្រូវពុំមានគំនិតជាតិនិយមខ្ពស់ មានការធ្វេសប្រហែស ពុំមានអ្នកជំនាញការច្បាស់លាស់ ឬមានអ្វីមួយជាលក្ខខណ្ឌដោយទុកចិត្តបរទេសណាមួយ ធ្វើឲ្យខ្មែរបាត់បង់ទឹកដី នោះជាបរាជ័យរបស់ខ្មែរក្នុងប្រវត្តិសាស្ត្រគួរឲ្យស្តាយ ដែលពុំអាចវិលត្រឡប់មកវិញ ។ មួយទៀតបញ្ហាវាស់ព្រំប្រទល់ដែននេះ កើតឡើងក្នុងពេលជាមួយគ្នា ត្រូវតែដោះស្រាយក្នុងពេលជាមួយគ្នាដែរ ។ រាជរដ្ឋាភិបាលខ្មែរនិងរដ្ឋាភិបាលវៀតណាមប្រកាសថា នឹងបោះបង្គោលព្រំដែនរវាងខ្មែរនិងវៀតណាមឲ្យរួចស្រេចនៅឆ្នាំ២០១២ ។ ដូច្នេះត្រូវយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នក្នុងការវាស់ព្រំប្រទល់ដែនរវាងប្រទេសទាំងបី ដើម្បីកុំឲ្យខ្មែរបាត់បង់ទឹកដី ពុំមែនយកចិត្តទុកដាក់តែខាងព្រំដែនថៃ ហើយធ្វេសប្រហែសព្រំប្រទល់វៀតណាមនិងលាវឡើយ ឬមានគំនិតថា ចាំដោះស្រាយខាងថៃសិន ទើបត្រឡប់មកដោះស្រាយខាងវៀតណាមដូចនេះឡើយ ។

បើពិនិត្យមើលពីក្រៅ បញ្ហាព្រំប្រទល់ខ្មែរ-វៀតណាមហាក់ដូចជាគ្មានបញ្ហា ដោយការព្រមព្រៀងស្ងប់ស្ងៀមរវាងរដ្ឋាភិបាលទាំងពីរខ្មែរ-វៀតណាម ប៉ុន្តែដល់ពិនិត្យមើលដល់ជំរៅ បញ្ហាកើតមានគួរឲ្យបារម្ភអំពីការបាត់បង់ទឹកដី ដោយភស្តុតាងប្រជាពលរដ្ឋខ្មែរស្រែកថាបាត់បង់ដីស្រែរបស់ខ្លួន ក្នុងការវាស់បោះបង្គោលព្រំប្រទល់ដែនខ្មែរ-វៀតណាមនេះ ។ អង្គការក្រៅរដ្ឋាភិបាលនិងគណបក្សមិនកាន់អំណាចក៏មានទស្សនៈដូចគ្នា រហូតចាប់អ្នកមានយោបល់ផ្ទុយដាក់គុកនិងផាកពិន័យតាមរយៈតុលាការមិនឯករាជ្យ ។ ប្រជាពលរដ្ឋមានមន្ទិលសង្ស័យអំពីសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥មិនស្របច្បាប់ ធ្វើឲ្យស្របច្បាប់ បារម្ភការបាត់បង់ទឹកដី ព្រោះវៀតណាមនៅមានអំណាចលើបក្សប្រជាជនកម្ពុជារហូតដល់សព្វថ្ងៃ ។ រឿងវៀតណាមផ្តួលរំលំខ្មែរក្រហម ធ្វើឲ្យខ្មែរដែលសេសសល់គេចផុតពីខ្មែរក្រហមសម្លាប់ជាបញ្ហាមួយ បញ្ហាមួយទៀតគឺវៀតណាមរំលោភលើសិទ្ធិខ្មែរ ធ្វើឲ្យខូចប្រយោជន៍ខ្មែរ ដែលខ្មែរជាម្ចាស់ទឹកដី ត្រូវតែទប់ទល់និងការពារ ។ អំពើនេះពុំមែនបានន័យថា រមិលគុណនិងប្រកាន់ជាតិសាសន៍ឡើយ ។ អ្នកនៅភូមិផងរបងជាមួយ ពុំអាចយកគ្នាជាសត្រូវរហូតឡើយ តែត្រូវតែជួយគ្នានិងគោរពសិទ្ធិគ្នាទៅវិញទៅមក ដោយពុំឈ្លានពានគ្នា ។ តាមប្រវត្តិសាស្ត្រ ទោះបីប្រទេសទាំងពីរ វៀតណាមនិងថៃ តែងតែមានជម្លោះជាមួយខ្មែរ រហូតខ្មែរបាត់បង់ទឹកដីអស់ជាច្រើនទៅប្រទេសទាំងពីរនេះក៏ដោយ ប៉ុន្តែនៅពេលនេះនិងទៅអនាគត បើប្រទេសទាំងពីរនេះឈប់ពង្រីកទឹកដីចូលមកប្រទេសកម្ពុជា ហើយវាស់ព្រំប្រទល់ដែនឲ្យបានត្រឹមត្រូវ នោះប្រទេសយើងនឹងរស់នៅភូមិផងរបងជាមួយគ្នាប្រកបដោយសុខសន្តិភាព ។

បញ្ហាជាមួយប្រទេសថៃ ខ្មែររួបរួមគ្នាជាឯកភាព ប៉ុន្តែការវាស់ព្រំប្រទល់ខាងវៀតណាមវិញ ខ្មែរមានទស្សនៈផ្សេងគ្នា ។ តើរាជរដ្ឋាភិបាលបង្ហាញភស្តុតាងនិងពន្យល់យ៉ាងណា ឲ្យអ្នកមានយោបល់ផ្ទុយ ជាពិសេសឲ្យប្រជាពលរដ្ឋខ្មែរទូទៅយល់ថា ការវាស់និងបោះបង្គោលព្រំដែនរវាងខ្មែរនិងវៀតណាម ជាការអនុវត្តដ៏ត្រឹមត្រូវ មិនបាត់បង់ទឹកដីខ្មែរសូម្បី១មិល្លីម៉ែត្រដូចរាជរដ្ឋាភិបាលប្រកាសអំពីព្រំដែនខ្មែរ-ថៃ ។ តើរាជរដ្ឋាភិបាលអាចដាក់មាន ៖ អញ្ជើញខ្មែរដែលមានយោបល់ផ្ទុយមកអង្គុយតុបង្ហាញយោបល់គ្នាទៅវិញទៅមកដោយផ្ទាល់ ដោយបង្ហាញឯកសារជាក់ស្តែងផង ។ ធ្វើយ៉ាងនេះមានគុណប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដែលបង្ហាញថា ខ្មែរនិងខ្មែរចេះអង្គុយនិយាយគ្នាពេលមានបញ្ហាជាតិ ប្រសើរជាងចង់ឈ្នះចង់ចាញ់គ្នាដោយប្រើតុលាការពុំយុត្តិធម៌ ធ្វើឲ្យខ្មែរចងគំនុំគ្នាតទៅទៀត ។ នេះជារូបមន្តដ៏ស័ក្តិសិទ្ធិសំរាប់ឲ្យខ្មែររួបរួមគ្នា មានឯកភាពជាតិប្រឆាំងនឹងសត្រូវបរទេស ។៚

❊ ❊

❊